ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ
លេខៈ ...៩៥...អ/សជភ

ភ្នំពេញ.ថ្ងៃទី២៧...ខែ...វិច្ឆិកា....ឆ្នាំ ២០០៦

# សេចក្តីណែនាំ

## ស្តីអំពី

## វិធានការធានាសុវត្ថិភាពនៃឯកសារសុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital

យោងអនុក្រឹត្យលេខ ៤៦ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ នីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី. អនុក្រឹត្យលេខ ៤៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ. ប្រកាសស្តីអំពីប្រតិភូកម្មហត្ថលេខាដល់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី. សេចក្តីណែនាំចុះថ្ងៃទី ២៨ ឧសភា ឆ្នាំ ២០០៥ ស្តីពីការចុះបញ្ជីបន្ត និងស្មារតី សិក្ខាសាលាស្តីពីការគ្រប់គ្រងថែរក្សាទិន្នន័យនៃការចុះបញ្ជីដីធ្លីតាមប្រព័ន្ធកុំព្យូទ័រ នាថ្ងៃទី ១៦-១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ នៅក្រុងព្រះសីហនុ និងដោយមានការឯកភាពពី ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ សូមធ្វើការណែនាំដូចតទៅ :

### ១- វិសាលភាពនៃសេចក្តីណែនាំ

សេចក្តីណែនាំនេះ អនុវត្តលើវិធានការធានាសុវត្ថិភាពជាមូលដ្ឋាន ដែលទាក់ទងនឹងការគ្រប់គ្រងឯកសារសុរិយោដី និងទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital របស់បណ្តាខេត្ត-ក្រុង ដោយយោងអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ ៤៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

### ២- ការថតចម្លងទិន្នន័យទុក (BACKUP )

ទិន្នន័យគោលនៃការចុះបញ្ជីដីធ្លីជា Digital ដែលមានមូលដ្ឋានទិន្នន័យ និងទិន្នន័យប្លង់សុរិយោដី ( Database and Map data) ត្រូវតែថតចម្លងទុកអោយបានរៀងរាល់ថ្ងៃ ។ នៅលើ Network Server មាន Folder

អាស័យដ្ឋាន លេខ ៨៨១-៨៨៣ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
MLMUPC Tel/Fax: (855-23) 215 660, E-mail: mlmupc@camnet.com.kh ; LMAP Tel/Fax: (855-23) 211 354, E-mail: lmap@camnet.com.kh